រឿង

# កូនខ្លាឃ្មុំខ្ញុំ



រឿង

# កូនខ្លាឃ្មុំខ្ញុំ



និពន្ធ  និងវិចិត្ររូបភាពដោយ លោក គីម សុគន្ធ

នៅក្នុងភូមិនាព្រៃជ្រៅមួយ មានលោកតា និងចៅស្រីរស់នៅ
ចិញ្ចឹមជីវិត ដោយដាក់អន្ទាក់យកសត្វ ។



ថ្ងៃមួយ  ពេលទៅដល់កន្លែងដាក់អន្ទាក់  លោកតាលាន់មាត់ថា «អ៊ីយ៉ាំ ! ថ្ងៃនេះ អន្ទាក់ជាប់បានមេខ្លាឃ្មុំមួយ ។ អ៊ូ ! វាមានកូនមួយទៀត ចាប់វាយកទៅផ្ទះសិន» ។



លុះមកដល់ផ្ទះ គាត់ប្រាប់ចៅ «នែ! ចៅស្រី យកកូនខ្លាឃ្មុំនេះទៅ
ចិញ្ចឹមអោយចំណីវាផង មេវាជាប់អន្ទាក់ងាប់ហើយ » ។



ចៅទទួលយកកូនខ្លាឃ្មុំពីលោកតា ហើយនិយាយ : « កូនខ្លាឃ្មុំតូចស៊ីទៅ! ដើម្បីឆាប់ធំទ្ធាលនឹងបានរត់លេងជាមួយគ្នាណា៎! » ។



អឺឡូវនេះ កូនខ្លាឃ្មុំធំបន្តិចហើយ ។ វាកំពុងរត់លេងជាមួយចៅស្រី ។ នាងរត់ផង សើចផង «ហាស់! ហាស់! ដេញមក ដេញមក សប្បាយណាស់!...»។



«...ឯងយោលខ្ញុំមក ។ យោលទៅ ៗ ហាស់! ហា៎! » ។



ពេលនោះ លោកតាក៏មកដល់ ។ ចៅស្រីស្រែកដោយក្ដីត្រេកអរ « នុះ៎! លោកតាមកពីព្រៃវិញហើយ ។ លោកតា! ខ្ញុំលេង ជាមួយកូនខ្លាឃ្មុំសប្បាយណាស់ ... » ។



« ...មើលហ្ន! លោកតាដាក់អន្ទាក់បានសត្វទៀតហើយ ។ តែខ្ញុំមិន
ចង់អោយលោកតាសំលាប់សត្វទៀតទេ » ។



ចៅស្រីនិយាយ ហើយក៏តាមមើលលោកតា ។ នាងលាន់មាត់ថា « តើលោកតាកំពុងធ្វើអ្វីហ្ន៎! អូ គាត់កំពុងតែបន់ថ្វាយអ្នកតាម្ចាស់ព្រៃ! គាត់ងប់នឹងការសំលាប់សត្វច្រើនឡើងៗ ហើយ »។



ថ្ងៃមួយ លោកតាត្រឡប់មកពីព្រៃវិញដោយដៃទទេ
ឥតបានអ្វីសោះ ។ មើលទៅប្រហែលជាអស់សត្វពីព្រៃហើយ ។



លោកតាពិបាកចិត្ត សំរាន្តគិតចង់ចាប់កូនខ្លាឃ្មុំយក
ទៅលក់ ដូរយកអាហារចិញ្ចឹមជីវិត ។



ប៉ុន្តែ ចៅស្រីនិយាយអង្វរ «ទេ ទេ! ខ្ញុំសុំអង្វរលោកតា កុំសំលាប់វា កុំយកវាទៅណា!»។



លោកតាក៏តបដោយក្រោធថា « យើះ! ចៅនេះ! កូនខ្លាឃ្មុំធំហើយ ឯងទុកវាធ្វើអ្វី ! ។ តានឹងចាប់វាហើយ ។ អោយវាមកតាភ្លាម តានឹងចងវា » ។ ចៅស្រីនៅតែនិយាយអង្វរលោកតា « ទេ ទេ! កុំយក កូនខ្លាឃ្មុំទៅណា! កូនខ្លាឃ្មុំនេះជារបស់ខ្ញុំ ! » ។



ចៅស្រីយំបណ្ដើរ និយាយបណ្ដើរ « ហ៊ឺៗ លោកតាចិត្ត អាក្រក់ណាស់! គាត់អត់អាណិតវាទេ ខ្ញុំនឹងទៅតាមខ្លាឃ្មុំខ្ញុំ » ។



លុះមកដល់ដើមឈើមួយ លោកតាក៏សំរាក ។ ចៅស្រីក៏នឹករកវិធីមួយ « អីយ៉ា! មានសំបុកឃ្មុំមួយនៅពីលើ នឹកឃើញហើយ រកអីគប់សិន! » ។



ពេលនោះ ចៅស្រីរកបានមែកឈើមួយ ក៏គប់សំដៅសំបុកឃ្មុំ ហើយស្រែកថា « ប្រយ័ត្នលោកតា! ឃ្មុំបែកសំបុកហើយ ! ឃ្មុំផ្អើលហើយ » ។





លោកតាត្រូវឃ្មុំទិច ក៏ស្ទុះរត់ទៅ ។ ចៅស្រីលាន់មាត់ថា « អ្ហូ! លោកតាឃ្មុំទិច រត់លឿនមែន! ។ អាណិតគាត់ដែរ ប៉ុន្តែ ត្រូវជួយកូនខ្លាឃ្មុំខ្ញុំសិន » ។





លុះត្រឡប់មកផ្ទះវិញ ចៅស្រីនិយាយទៅកាន់លោកតា «សូមទោសលោកតា! ខ្ញុំធ្វើបែបនេះ ព្រោះតែ ខ្ញុំចង់បានកូនខ្លាឃ្មុំមកវិញតែប៉ុណ្ណោះ» ។





លោកតាក៏និយាយតបវិញ « មិនអីទេចៅ! កូនខ្លាឃ្មុំនៅជាមួយយើងក៏ល្អដែរ គ្រាន់បានជាគ្នានឹងចៅ ។ តាសន្យាឈប់ដាក់អន្ទាក់សត្វទៀតហើយ » ។

« ហាស់ ហា! លោកតាខ្ញុំឈប់សំលាប់សត្វហើយ » ចៅស្រីសើចដោយទឹកចិត្តរីករាយ ៕

xxxxx ចប់ xxxxx



# រឿង កូនខ្លាឃ្មុំខ្ញុំ

និពន្ធដោយ លោក គឹម សុគន្ធ

គូររូបដោយ លោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្មគ្រ័ចិត្ត(SVA)

បោះពុម្ពឆ្នាំ២០០៤

